ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិរបបសន្តិសុខសង្គម

លេខ : ០២៣/១៥ ប.ស.ស

# សេចក្តីជូនដំណឹង

បេឡាជាតិរបបសន្តិសុខសង្គម មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ លោក លោកស្រី ជាម្ចាស់នាយកសហគ្រាស គ្រឹះស្ថាន សាមីជនរងគ្រោះ ឬអ្នកតំណាងនៃជនរងគ្រោះ ទាំងអស់មេត្តាជ្រាបថា: រយៈកាលកន្លងមកមានតំណាងសហគ្រាស គ្រឹះស្ថាន សាមីជនរងគ្រោះ និងអ្នកតំណាងជនរងគ្រោះជាច្រើន បានមកទទួលយក "***សេចក្តីសម្រេចផ្តល់តាវកាលិកហានិភ័យការងារ*** "ពីប.ស.ស រួចហើយ ប៉ុន្តែពុំទាន់បានទៅដកប្រាក់ពីធនាគារអេស៊ីលីដាភីអិលស៊ីនៅឡើយ ដោយបានទុកសេចក្តីសម្រេចនេះរយៈពេលជាច្រើនខែដែលជាហេតុបណ្តាលឱ្យបេឡាជាតិរបបសន្តិសុខសង្គមមានការលំបាកក្នុងការគ្រប់គ្រងនិងត្រួតពិនិត្យសាច់ប្រាក់។

អាស្រ័យហេតុនេះ សូមតំណាងសហគ្រាសគ្រឹះស្ថាន សាមីជនរងគ្រោះ និងអ្នកតំណាងជនរងគ្រោះដែលបានទទួលសេចក្តីសម្រេចផ្តល់តាវកាលិកហានិភ័យការងារនេះរួចហើយ ត្រូវទៅដកសាច់ប្រាក់ឱ្យបានរួសរាន់ក្នុង**រយៈពេល ៣ ខែ** ចាប់ពីកាលបរិច្ឆេទចេញសេចក្តីជូនដំណឹងនេះ បើពុំនោះសោត សេចក្តីសម្រេចផ្តល់តាវកាលិកហានិភ័យនោះ ត្រូវចាត់ទុកជាមោឃៈ។

ចំពោះ" ***សេចក្តីសម្រេចផ្តល់តាវកាលិកហានិភ័យការងារ*** " ដែលនឹងចេញប្រើប្រាស់ចាប់ពីឆ្នាំ២០១៦តទៅ **មានសុពលភាពត្រឹមរយៈពេល ៦ ខែ គិតចាប់ពីកាលបរិច្ឆេទនៃការចុះហត្ថលេខា។**

បេឡាជាតិរបបសន្តិសុខសង្គមសង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រីជាម្ចាស់ នាយកសហគ្រាស គ្រឹះស្ថាន សាមីជនរងគ្រោះ ឬអ្នកតំណាងជនរងគ្រោះទាំងអស់សហការ និងអនុវត្តតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១៥

**នាយកបេឡាជាតិរបបសន្តិសុខសង្គម**

**អ៊ុក សមវិទ្យា**

អាសយដ្ឋានអគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣-៨៨ ២៤ ៣៤ , ០២៣ ៩៩ ៨៤ ១៧ ០២៣-៩៩ ៨៤ ១៨ , ០២៣ ៩៩ ៨៤ ១៩
ទូរសារ : ០២៣ ៨៨ ២៦ ២៣ , ប្រអប់សំបុត្រ P.O.Box 70
Website : www.nssf.gov.kh